ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
PHNOM PENH WATER SUPPLY AUTHORITY

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
លេខៈ ១៤៤៣ន.លា

ថ្ងៃ ចន្ទ ៤កើត ខែ ភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ២០២៣

**សេចក្តីជូនដំណឹង**
**ស្តីពី**
**ការអញ្ជើញចូលរួមដេញថ្លៃ**

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់នូវទំនិញ ដូចខាងក្រោមៈ

១-កញ្ចប់"ក": ការផ្គត់ផ្គង់គ្រឿងបន្លាស់ប្រព័ន្ធមេកានិច
២-កញ្ចប់"ខ": ការផ្គត់ផ្គង់គ្រឿងបន្លាស់ប្រព័ន្ធអគ្គិសនី
៣-កញ្ចប់"គ": ការផ្គត់ផ្គង់គ្រឿងបន្លាស់ប្រព័ន្ធក្លរីរាវ
៤-កញ្ចប់"ឃ": ការផ្គត់ផ្គង់ក្លរម្សៅ

ឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ (រួមទាំងសេចក្តីណែនាំ) មានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានអាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ចាប់ពីថ្ងៃអង្គារ ទី១៩ ខែកញ្ញា ឆ្នាំ២០២៣ តទៅ រៀងរាល់ម៉ោងធ្វើការ (៨:០០នាទីដល់ ១៦:៣០នាទី) ដល់ថ្ងៃអង្គារ ទី២៤ ខែតុលា ឆ្នាំ២០២៣ ត្រឹមវេលាម៉ោង ១៦:០០នាទី ក្នុងមួយច្បាប់តម្លៃ ៤០០,០០០រៀល សម្រាប់កញ្ចប់"ក",៣០០,០០០រៀល សម្រាប់ កញ្ចប់"ខ" និង២០០,០០០រៀល សម្រាប់កញ្ចប់"គ,ឃ"។

កាលបរិច្ឆេទបង្ហាញគ្រឿងបន្លាស់ប្រព័ន្ធមេកានិច, គ្រឿងបន្លាស់ប្រព័ន្ធអគ្គិសនី និងគ្រឿងបន្លាស់ប្រព័ន្ធក្លរីរាវ ថ្ងៃពុធ ទី២៧ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង០៩:០០នាទី។ ការដែលមិនបានចូលរួមពិនិត្យនូវគ្រឿងបន្លាស់ប្រព័ន្ធមេកានិច, គ្រឿងបន្លាស់ប្រព័ន្ធអគ្គិសនី និងគ្រឿងបន្លាស់ប្រព័ន្ធក្លរីរាវ គឺជាការទទួលខុសត្រូវរបស់អ្នកចូលរួមដេញថ្លៃ ផ្ទាល់។

កាលបរិច្ឆេទឈប់ទទួល និងបើកសំណើដេញថ្លៃគឺ ថ្ងៃពុធ ទី២៥ ខែតុលា ឆ្នាំ២០២៣ កញ្ចប់"ក" វេលាម៉ោង ១៤:០០នាទី, កញ្ចប់"ខ"វេលាម៉ោង១៤:១៥នាទី, កញ្ចប់"គ"វេលាម៉ោង១៤:៣០នាទី និងកញ្ចប់"ឃ"វេលាម៉ោង ១៤:៤៥នាទី នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ជាន់ទី១) តាមអាសយដ្ឋានខាងលើ។

គ្រប់ពាក្យដេញថ្លៃទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវប្រាក់កក់ធានាការដេញថ្លៃដែលមានចំនួនដូចបានកំណត់ក្នុងឯកសារដេញថ្លៃ។

អ្នកដេញថ្លៃមានសិទ្ធិជ្រើសរើសកញ្ចប់មួយ ឬទាំងអស់។ ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ (ទូរស័ព្ទទាក់ទងលេខ ០១៧ ៨១១ ៩១១)។

**ជ. គណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធាន**

**ជូ ផល្លា**

ចម្លងជូនៈ
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
"ដើម្បីជ្រាបជាព័ត៌មាន"
-ឯកសារ-កាលប្បវត្តិ